# សាលារៀនមានសុវត្ថិភាពគឺជាសាលារៀនមានប្រសិទ្ធភាព

## វិធីសាស្ត្រសំរាប់មាតាបិតា

ការដឹងថា កូនលោកអ្នកកំពុងទទួលការសម្លុតធ្វើបាប ឬថាកូនលោកអ្នកកំពុងសម្លុតធ្វើបាបអ្នកដទៃ អាចធ្វើឲ្យលោកអ្នកលំបាកចិត្តនិងអាក់អន់ចិត្តណាស់។ ដើមដំបូង មាតាបិតាភាគច្រើនមានការខឹងសំបា អារម្មណ៍ច្របូកច្របល់ និងថាខ្លួនមានកំហុស។

គេបានបង្កើតព័ត៌មានតទៅនេះដើម្បីផ្តល់ជូនលោកអ្នកនូវវិធីសាស្ត្រមានប្រយោជន៍ សំរាប់ដោះស្រាយឧប្បត្តិហេតុនៃការសម្លុតធ្វើបាប។



## តើការសម្លុតធ្វើបាបគឺជាអ្វីទៅ?

ការសម្លុតធ្វើបាបគឺនៅពេលដែលជនម្នាក់ ឬជនមួយក្រុមដែលមានកម្លាំងអំណាចខ្លាំងនៅគ្រានោះ ប្រព្រឹត្តអំពើដោយចេតនា ដើម្បីធ្វើឲ្យជនម្នាក់ទៀតដែលមានកម្លាំងអំណាចទន់ខ្សោយជាង អាក់អន់ចិត្ត ឬឈឺចាប់លើសពីគ្រាមួយដង។ ការសម្លុតធ្វើបាបមានរួមទាំងការសម្លុតធ្វើបាបលើរាងកាយ ដូចជាការវាយដំ ការសម្លុតធ្វើបាបតាមពាក្យសម្តី ដូចជាដាក់ងារដែលមានឈ្មោះមិនល្អ និងការសម្លុតធ្វើបាបដោយប្រយោល ដូចជាការនិយាយផ្សព្វផ្សាយពាក្យចចាមអារ៉ាម។

## ការសម្លុតធ្វើបាប មិនមែនជា

- ស្ថានការណ៍មួយដែលមានទំនាស់រវាងគ្នា - ពោលគឺកម្លាំងអំណាចមានស្មើគ្នា នៅគ្រាដែលសិស្សទាំងពីរនាក់មានការអាក់អន់ចិត្ត ហើយជាធម្មតាចង់ឲ្យមានដំណោះស្រាយទៅនឹងបញ្ហានោះ។
- ការបដិសេធមិនរាប់អានឬការមិនចូលចិត្ត (លើកលែងតែជាអំពើម្តងហើយម្តងទៀត ហើយតំរង់ទៅកាន់ជនជាក់លាក់ណាម្នាក់)។
- ហេតុការណ៍ខ្លីៗទោលទាំងឡាយនៃភាពកំណាចឬអាក្រក់ ឬអំពើពាសវាលពាសកាលនៃភាពឃឃ្លើនឬ បំភិតបំភ័យ។



## តើវិធីណាទៅដែលអាចឲ្យខ្ញុំដឹងថា កូនខ្ញុំកំពុងទទួលការសម្លុតធ្វើបាប?

សញ្ញាខ្លះដែលកុមារកំពុងទទួលការសម្លុតធ្វើបាប រួមមាន:

- ការគ្មានបំណង ឬបដិសេធមិនទៅសាលារៀន
- អារម្មណ៍មិនស្រួលខ្លួននៅពេលព្រឹក
- គេចមិនទៅរៀន
- ធ្វើកិច្ចការសាលារៀនរបស់ខ្លួនមិនបានល្អ
- មិនចូលចិត្តជំនុំចំណោម ចាប់ផ្តើមនិយាយត្រដិត ខ្វះការទុកចិត្តលើខ្លួនឯង
- យំរហូតទាល់តែគេងលក់ យល់សប្តិអាក្រក់
- សុំលុយ ឬចាប់ផ្តើមលួច (ដើម្បីយកទៅឲ្យអ្នកសម្លុតធ្វើបាប)
- មិនព្រមនិយាយអំពីរឿងរ៉ាវដែលបានកើតមានឡើង
- មានស្នាមជាំ ស្នាមមុត ស្នាមក្រចៅ ដោយគ្មានប្រាប់មូលហេតុ
- ចាប់ផ្តើមសម្លុតធ្វើបាបកុមារឯទៀត ឬបងប្អូនបង្កើត
- ទៅជាគឃ្លើនកោងកាច និងគ្មានភាពសមហេតុផល

យកលំនាំចេញពី *Kidscape* មាននៅឯ **www.kidscape.org.uk/parents/signsof.shtml**



## តើខ្ញុំអាចធ្វើអ្វី បើកូនខ្ញុំកំពុងទទួលការសម្លុតធ្វើបាប?

**ជំហានទី 1:** ស្តាប់កូនលោកអ្នកឲ្យបានម៉ត់ចត់ ហើយបង្ហាញការបារម្ភនិងការគាំទ្រ.

**ជំហានទី 2:** ផ្តល់ឱវាទសមហេតុផល - កុំជំរុញទឹកចិត្តកូនលោកអ្នកឲ្យប្រឈមតបតទៅវិញ។ អំពើនេះនឹងទំនងជាបង្កើនការសម្លុតធ្វើបាប។

**ជំហានទី 3:** ជួយកូនលោកអ្នកក្នុងការបង្កើតវិធីសាស្ត្រវិជ្ជមានដោយមានរួមទាំង:

- ការនិយាយថា កុំរំខានខ្ញុំ ហើយដើរចេញដោយស្ងប់ស្ងាត់
- ចៀសវាងស្ថានការណ៍ទាំងឡាយដែលប្រហែលជាធ្វើឲ្យកូនលោកអ្នកទទួលការសម្លុតធ្វើបាបតទៅទៀត
- បង្កើតចំណងមិត្តភក្តិថ្មី។

**ជំហានទី 4:** សួរកូនលោកអ្នកនូវសំណួរដូចតទៅ ដើម្បីឲ្យយល់នឹងថា តើមានលំនាំមួយដែលកើតមានម្តងហើយម្តងទៀតឬទេ:

- តើអ្វីទៅដែលជាឧប្បត្តិហេតុនេះ ហើយវាបានកើតមានឡើងនៅទីណានិងពេលណា?
- តើអ្នកណាទៅដែលបានចូលរួមនៅក្នុងគ្រានីមួយៗ?
- តើមានជនណាមួយដែលបានឃើញឧប្បត្តិហេតុនេះឬទេ ហើយបើមាន តើជននោះគឺជាអ្នកណា?
- តើមានដំណោះស្រាយអ្វីទៅដែលបានសាកល្បងប្រើមកទល់នឹងពេលនេះ?
- ឈ្មោះរបស់គ្រូបង្រៀនទាំងអស់ដែលដឹងអំពីបញ្ហានេះ។

**ជំហានទី 5:** ធ្វើការជាមួយសាលារៀនរបស់កូនលោកអ្នកដើម្បីដោះស្រាយបញ្ហានេះ។ សាលារៀន ប្រកាន់ការទទួលខុសត្រូវរបស់ខ្លួនដ៏មុតមាំណាស់លើបញ្ហាទាក់ទងនឹងឥរិយាបថសម្លុតធ្វើបាប ហើយសាលារៀនរឹតតែទទួលជោគជ័យនៅពេលដែលមាតាបិតាធ្វើការជាមួយសាលារៀន ដើម្បីដោះស្រាយបញ្ហាសម្លុតធ្វើបាប។

*សូមចងចាំថា បើលោកអ្នកមិនបានដឹងថា កូនលោកអ្នកកំពុងទទួលការសម្លុតធ្វើបាបទេ គ្រូបង្រៀនរបស់កូនលោកអ្នកប្រហែលជាមិនដឹងរឿងនេះផងដែរ។*

លោកអ្នកគួរ::

- ធ្វើការណាត់ជួបជាមួយគ្រូបង្រៀនរបស់កូនលោកអ្នក និងកត់ទុកនូវចំណុចទាំងឡាយដែលលោកអ្នកចង់ពិភាក្សានៅមុនពេលប្រជុំ។
- នៅឯការប្រជុំ សូមព្យាយាមរក្សាអារម្មណ៍ស្ងប់ស្ងាត់ និងផ្តល់ព័ត៌មានតាមវិធីមួយដែលធ្វើឲ្យច្បាស់ថា លោកអ្នកនិងសាលារៀនកំពុងធ្វើការជាដៃគូ ក្នុងការខិតខំដោះស្រាយបញ្ហានេះ។

សាលារៀននឹងត្រូវការពេលវេលាដើម្បីស៊ើបអង្កេត ហើយនិយាយជាមួយនឹងគ្រូបង្រៀន និងប្រហែលជាមួយនឹងសិស្សឯទៀត។

**ជំហានទី 6:** លោកអ្នកអាចទូរស័ព្ទនៅពេលក្រោយមកទៀត ដើម្បីឲ្យដឹងថា តើសាលាបានធ្វើអ្វីឬទេ ឬមួយក៏សួរសាលារៀនថា តើពេលណាទៅដែលលោកអ្នកអាចរំពឹងទទួលដំណឹងពីសាលារៀន។



**ជំហានទី 7:** ធ្វើការជាមួយសាលារៀនដើម្បីបង្កើតផែនការមួយសំរាប់ដោះស្រាយស្ថានការណ៍គ្រាសព្វថ្ងៃ និងឧប្បត្តិហេតុសម្លុតធ្វើបាបនៅថ្ងៃមុខទៀត។ មុនពេលលោកអ្នកចាកចេញទៅ សូមសុំឲ្យសាលារៀនបកស្រាយអំពីជំហានបន្ទាប់នៅក្នុងផែនការនោះ។

**ជំហានទី 8:** បើចាំបាច់ សុំឲ្យមានការចូលរួមពីអ្នកពិគ្រោះឱវាទរបស់សាលារៀន។

**ជំហានទី 9:** ជំរុញទឹកចិត្តកូនលោកអ្នកឲ្យរាយការណ៍អំពីឧប្បត្តិហេតុសម្លុតធ្វើបាបណាមួយទៀត ប្រាប់គ្រូបង្រៀនដែលកូនលោកអ្នកទុកចិត្តនៅឯសាលារៀន។

## តើខ្ញុំមិនគួរធ្វើអ្វី បើកូនខ្ញុំកំពុងទទួលការសម្លុតធ្វើបាប?

- កុំទាក់ទងសិស្សណាមួយផ្សេងទៀតដោយផ្ទាល់ដែលលោកអ្នកជឿថា អាចមានការទាក់ទងនៅក្នុងការសម្លុតធ្វើបាបកូនលោកអ្នក។
- កុំព្យាយាមដោះស្រាយបញ្ហាទាំងនេះជាមួយមាតាបិតាសិស្សនោះ។ ជាធម្មតា អំពើនេះគ្មានប្រសិទ្ធភាពទេ និងធ្វើឲ្យស្ថានការណ៍រឹតតែដុនដាបខ្លាំងថែមទៀត។

## តើខ្ញុំគួរធ្វើអ្វី បើកូនខ្ញុំកំពុងសម្លុតធ្វើបាបអ្នកដទៃ?

- ឆ្លើយតបដោយស្ងប់ស្ងាត់និងមិនប្រកែកការពារ ហើយប្តូរផ្តាច់ក្នុងការធ្វើការជាមួយសាលារៀនដើម្បី ដោះស្រាយបញ្ហានេះតាមវិធីដែលមានប្រយោជន៍។
- ចាត់ទុកស្ថានការណ៍នេះថាជាឱកាសមួយសំរាប់ឲ្យកូនលោកអ្នករៀនសូត្រមេរៀនអំពីការលូតលាស់ដ៏សំខាន់។

## តើខ្ញុំមិនគួរធ្វើអ្វី បើកូនខ្ញុំកំពុងសម្លុតធ្វើបាបអ្នកដទៃ?

- កុំទាក់ទងសិស្សដែលកូនលោកអ្នកសម្លុតធ្វើបាបដោយផ្ទាល់ ឬគ្រួសាររបស់សិស្សនោះ ឬព្យាយាមទាក់ទាញមាតាបិតាឯទៀតឲ្យកាន់ជើងកូនលោកអ្នក។

## តើខ្ញុំអាចធ្វើអ្វីទៅដើម្បីកាត់បន្ថយការសម្លុតធ្វើបាបនៅសាលារៀន?

- រាយការណ៍ប្រាប់សាលារៀននូវឧប្បត្តិហេតុនៃការសម្លុតធ្វើបាបទាំងអស់ មិនមែនគ្រាន់តែឧប្បត្តិហេតុដែលកើតមានចំពោះកូនលោកអ្នកផ្ទាល់ឡើយ។
- ប្រាប់កូនលោកអ្នកឲ្យដឹងថា លោកអ្នកជំទាស់ខ្លាំងយ៉ាងណាដែរចំពោះការសម្លុតធ្វើបាប និងមូលហេតុ។
- គួរចៀសវាងការសម្លុតធ្វើបាបរាល់ប្រភេទទាំងអស់នៅឯផ្ទះ ហើយគួរធ្វើគំរូនិងជំរុញទឹកចិត្តនូវការគោរពអ្នកដទៃ។
- និយាយទៅកាន់កូនលោកអ្នកអំពីគុណសម្បត្តិដែលទាក់ទងនឹងការយកចិត្តទុកដាក់ចំពោះមិត្តភាព និងបង្គាប់ទឹកចិត្តកូនលោកអ្នកកុំឲ្យស្ថិតនៅក្នុង“មិត្តភាព”ដែលគេមិនគោរពឬប្រព្រឹត្តអំពីមិនគប្បីចំពោះកូនលោកអ្នក។

## វិបសៃមានប្រយោជន៍

សាលារៀនមានសុវត្ថិភាព គឺជាសាលារៀនមានប្រសិទ្ធភាព:
(Safe Schools are Effective Schools):
**www.sofweb.vic.edu.au/wellbeing/safeschools/bullying/index.htm**

បទបញ្ញត្តិរបស់សិស្ស
(Student Code of Conduct):
**www.sofweb.vic.edu.au/wellbeing/welfare/conduct.htm**

ការសម្លុតធ្វើបាប មិនចង់បានឡើយ!
(Bullying. No Way!):
**www.bullyingnoway.com.au**



safe schools are effective schools